International Labour Organization

better factories Cambodia

# សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាគំរោង (PAC) នៃគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ស្តីពី ការចេញផ្សាយរបាយការណ៍សំយោគលើកទី ២៧ របស់អង្គការពលកម្មអន្តរជាតិ (ILO) ស្តីពីល័ក្ខខ័ណ្ឌការងារ ក្នុងវិស័យកាត់ដេរនៅកម្ពុជា

១. នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២ គណៈកម្មការប្រឹក្សាគំរោង របស់***គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*** នៃអង្គការពលកម្មអន្តរជាតិ បានជួបប្រជុំនៅទីក្រុងភ្នំពេញដើម្បីពិនិត្យមើល និង ផ្តល់ការយល់ព្រមទៅលើរបាយការណ៍សំយោគលើកទី ២៧ របស់អង្គការពលកម្មអន្តរជាតិស្តីពីល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរនៅកម្ពុជា។ គណៈកម្មការប្រឹក្សាគំរោងមានអ្នកតំណាងមកពី រាជរដ្ឋាភិបាលកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និង សហជីពកម្ពុជា ។

២. សមាជិកគណៈកម្មការប្រឹក្សាគំរោង ស្វាគមន៍ចំពោះការចេញផ្សាយរបាយការណ៍នេះ ដែលបង្ហាញព័ត៌មានស្តីពីល័ក្ខខ័ណ្ឌការងារ ដែលបានបង្កើតឡើងតាមរយៈការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានដោយស្វ័យប្រវត្តិ (IMS) របស់គំរោង ។

៣. យើងកត់សំគាល់ថាមានការខិតខំប្រឹងប្រែងអនុលោមតាមច្បាប់ចំពោះរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ដែលបានចុះឃ្លាំមើលដោយគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា។ បើទោះជាយ៉ាងនេះក្តី យើងនៅមានចន្លោះខ្វះខាតដើម្បីកែលំអ។

៤. យើងសូមបន្ត និង បង្ហាញនូវការគាំទ្ររបស់យើងចំពោះគំរោងរបស់អង្គការពលកម្មអន្តរជាតិ ហើយក៏សូមអំពាវនាវដល់ភាគីដែលពាក់ព័ន្ធ អោយបន្តការរួមចំណែកបន្ថែមទៀតក្នុងការកែលំអល័ក្ខខ័ណ្ឌការងារ អោយកាន់តែមានលក្ខណៈល្អប្រសើរនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់នៅកម្ពុជា ។

ភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២